ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :១៣..ស.ម.ន...

សារលិខិត
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ផ្ញើជូនជនរួមជាតិកម្ពុជា
ក្នុងឱកាសបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២

-សម្តេចព្រះអគ្គមហាសង្ឆរាជាធិបតី សម្តេចព្រះសង្ឆរាជ សម្តេចព្រះរាជាគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីសក្តារៈ
-សម្តេច ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ជាទីមេត្រី
-បងប្អូនជនរួមជាតិ ដែលកំពុងរស់នៅក្នុងនិងក្រៅប្រទេស ជាទីស្នេហា

ទូលបង្គំ ខ្ញុំព្រះករុណា ខ្ញុំ សូមចូលរួមអំណរសាទរក្នុងទិវាបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ដែលប្រព្រឹត្តទៅនាថ្ងៃអាទិត្យ ១០កើត ថ្ងៃចន្ទ ១១កើត និងថ្ងៃអង្គារ ១២កើត ខែចេត្រ ត្រូវនឹងថ្ងៃទី១៤ ទី១៥ និងថ្ងៃទី១៦ ខែមេសា ឆ្នាំ២០១៩ ជាមួយបងប្អូនជនរួមជាតិទាំងអស់ដែលកំពុងរស់នៅក្នុងនិងក្រៅប្រទេស ប្រកបដោយក្តីសោមនស្សរីករាយ សិរីសួស្តី និងជ័យមង្គលដ៏ឧត្តុង្គឧត្តមក្នុងក្រុមគ្រួសារនិងសង្គមជាតិទាំងមូល។

ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២ ឆ្នាំនេះ ប្រព្រឹត្តទៅស្របពេលដែលរាជរដ្ឋាភិបាលបានចាប់ផ្តើមអនុវត្តកម្មវិធីនយោបាយនិងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ សម្រាប់នីតិកាលទី៦នៃរដ្ឋសភា និងនៅក្នុងបរិការណ៍ដែលរាជរដ្ឋាភិបាលបន្តទទួលបាននូវទំនុកចិត្តដ៏ច្រើនលើសលប់ចេញពីឆន្ទៈរបស់ប្រជាជនកម្ពុជានៅទូទាំងប្រទេស ក្នុងការដឹកនាំប្រទេសជាតិសម្រាប់រយៈពេល៥ឆ្នាំបន្តទៀត។

រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភា ដែលបានប្រសូតចេញពីការបោះឆ្នោត កាលពីថ្ងៃអាទិត្យ ទី២៩ ខែកក្កដា ឆ្នាំ២០១៨ កន្លងទៅ ក្នុងលក្ខណៈសេរី យុត្តិធម៌ ត្រឹមត្រូវ តម្លាភាព និងក្នុងបរិយាកាសស្ថិរភាពនយោបាយ ស្របទៅតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ដោយមានប្រជាពលរដ្ឋចូលរួមរហូតដល់ ៨៣,០២% នៃចំនួនអ្នកមានឈ្មោះក្នុងបញ្ជីអ្នកបោះឆ្នោត បាននិងកំពុងបន្តបេសកកម្មដ៏ឧត្តុង្គឧត្តមជាប្រវត្តិសាស្ត្ររបស់ខ្លួន ជាមួយនឹងការប្តេជ្ញាចិត្តយ៉ាងមុតមាំឥតរាថយ និងកាន់តែស្វាហាប់ជាងពេលណាៗទាំងអស់ ក្នុងការបម្រើប្រជាជនទ្វេដង ក៏ដូចជាក្នុងការពន្លឿនកិច្ចអភិវឌ្ឍ និងជំរុញអនុវត្តការកែទម្រង់កាន់តែស៊ីជម្រៅ និងទូលំទូលាយក្នុងគ្រប់វិស័យឆ្ពោះទៅរកអនាគតមួយដ៏រុងរឿងស្របតាមឆន្ទៈនិងបំណងប្រាថ្នាដ៏ពិសិដ្ឋរបស់ប្រជាជននៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

ឆ្នាំចាស់ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ បានកន្លងផុតទៅ ដោយផ្លាស់ជំនួសវិញនូវឆ្នាំថ្មី ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ទោះបីកម្ពុជាបានប្រឈមនឹងឧបសគ្គគ្រប់បែបយ៉ាងទាំងក្នុងនិងក្រៅប្រទេសក៏ដោយ ក៏រាជរដ្ឋាភិបាលបន្តកសាងប្រទេសជាតិឲ្យមានវឌ្ឍនភាពលើគ្រប់វិស័យ ការពារឲ្យបានឯករាជ្យជាតិ

សន្តិភាព អធិបតេយ្យ និងបូរណភាពទឹកដី ការពារសមិទ្ធផលសង្គមជាតិ ទប់ស្កាត់ការជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងកម្ពុជា ប្រឆាំងជាច់ខាតរាល់សកម្មភាពដែលពាក់ព័ន្ធនឹងបដិវត្តន៍ពណ៌ ឬការញុះញង់ណាមួយ បង្កឲ្យមានអស្ថិរភាពនយោបាយ ឬចលាចលក្នុងសង្គមជាតិកម្ពុជា។ ជាលទ្ធផល កម្ពុជារក្សាបាននូវសុខសន្តិភាព ឯករាជ្យជាតិ និងអធិបតេយ្យភាពរបស់ខ្លួន ព្រមទាំងបញ្ចៀសបាននូវគ្រោះមហន្តរាយជាថ្មីសម្រាប់ពលរដ្ឋកម្ពុជា ដែលកំពុងចូលរួមយ៉ាងសស្រាកសស្រាំក្នុងជីវភាពរស់នៅប្រចាំថ្ងៃ និងកិច្ចអភិវឌ្ឍប្រទេសជាតិ។

ដោយឈរលើមូលដ្ឋានដែលប្រទេសជាតិមានសន្តិសុខ និងសន្តិភាពពេញលេញនេះ ក្នុងឆ្នាំ២០១៨ កន្លងទៅ តាមការប៉ាន់ស្មាន សេដ្ឋកិច្ចកម្ពុជាសម្រេចបានកំណើន **៧,៥%**។ កំណើនដ៏រឹងមាំនេះ ត្រូវបានឆ្លុះបញ្ចាំងតាមរយៈការរីកចម្រើននៃវិស័យឧស្សាហកម្ម កម្មន្តសាល សំណង់ កសិកម្ម និងសេវាកម្ម ដូចជាទេសចរណ៍និងអចលនទ្រព្យជាដើម។ គួរកត់សម្គាល់ថា កម្ពុជាកំពុងតែផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ចពីប្រទេសដែលពឹងផ្អែកលើវិស័យកសិកម្ម ទៅជាប្រទេសដែលពឹងផ្អែកលើវិស័យឧស្សាហកម្មនិងសេវាកម្ម។ កម្ពុជាបានអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចប្រកបដោយភាពប្រុងប្រយ័ត្ន និងធ្វើឲ្យសេដ្ឋកិច្ចមានស្ថិរភាព ហើយបានជំរុញនិងលើកកម្ពស់ការធ្វើពិពិធកម្មសេដ្ឋកិច្ច ភាពប្រកួតប្រជែង ព្រមទាំងការផលិតនិងការប្រើប្រាស់ក្នុងស្រុក។ ទំហំពាណិជ្ជកម្មអន្តរជាតិមានប្រមាណ**ជាង ២៩ ៨០០លានដុល្លារអាមេរិក** ចំណែកឯការនាំចេញមានប្រមាណ**ជាង ១២ ៨០០លានដុល្លារអាមេរិក**។ អត្រាប្តូរប្រាក់មានស្ថិរភាព អត្រាអតិផរណាស្ថិតក្នុងកម្រិតទាប និងអាចគ្រប់គ្រងបាន ទុនបម្រុងអន្តរជាតិបានកើនជារៀងរាល់ឆ្នាំ អាស្រ័យដោយវិនិយោគផ្ទាល់ពីបរទេសមានកំណើនល្អ និងតុល្យភាពជញ្ជីងទូទាត់ក៏មានភាពកាន់តែប្រសើរឡើងដែរ។ រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសពីការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការកែទម្រង់ឲ្យកាន់តែស៊ីជម្រៅ និងលើកទឹកចិត្តដល់អ្នកវិនិយោគឱ្យមកបោះទុននៅកម្ពុជាឲ្យកាន់តែច្រើន ខណៈដែលយើងបានរៀបចំការសម្រួលពាណិជ្ជកម្ម ពង្រឹងភាពប្រកួតប្រជែងជូនវិនិយោគិននៅកម្ពុជា ក្រោមដំបូលសន្តិភាព លទ្ធិប្រជាធិបតេយ្យ សេរីភាពពហុបក្ষ ដោយមិនមានការរើសអើង។

កម្រិតជីវភាពរបស់ប្រជាជនកាន់តែមានភាពល្អប្រសើរ ដែលបង្ហាញឲ្យឃើញតាមរយៈសូចនាការសង្គម ជាពិសេសការកើនឡើងនៃផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) ជាមធ្យមសម្រាប់មនុស្សម្នាក់ពី **១ ០៤២ដុល្លារអាមេរិក** ក្នុងឆ្នាំ២០១៣ ដល់ប្រមាណ **១ ៥៦៣ដុល្លារអាមេរិក** ក្នុងឆ្នាំ២០១៨។ អត្រាភាពក្រីក្រមានការធ្លាក់ចុះយ៉ាងខ្លាំងពី **៥៣,៥%** ក្នុងឆ្នាំ២០០៤ បានធ្លាក់មកក្នុងរង្វង់ **៥%** ក្នុងឆ្នាំ២០១៨ និងបន្តធ្លាក់ចុះថែមទៀតនៅឆ្នាំ២០១៩នេះ ហើយគម្លាតនៃប្រាក់ចំណូលរបស់ប្រជាជន ក៏មានការធ្លាក់ចុះជាលំដាប់ផងដែរ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលក៏បានរៀបចំបង្កើនប្រាក់ចំណូលជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ ឲ្យទទួលបាននូវប្រាក់បៀវត្សកាន់តែខ្ពស់ពីមួយឆ្នាំទៅមួយឆ្នាំ ដែលក្នុងឆ្នាំ២០១៨កន្លងទៅ ប្រាក់បៀវត្សរបស់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធបានកើនដល់កម្រិ**តជាង ១លានរៀល** ហើយការបើកបៀវត្សបានធ្វើទាន់ពេលវេលាគឺ**បើក២ដង** ក្នុងមួយខែ តាមប្រព័ន្ធធនាគារ។

ក្នុងឆ្នាំកន្លងទៅ រាជរដ្ឋាភិបាលសម្រេចបានការងារធំៗជាច្រើនវិស័យ ក្នុងនោះការកសាងហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ស្ពាន ត្រូវបានបន្តអនុវត្តជាប់ជាប្រចាំ ស្របតាមការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដើម្បីបម្រើដល់វិស័យដឹកជញ្ជូន និងការធ្វើដំណើររបស់ប្រជាពលរដ្ឋ។ រហូតមកដល់បច្ចុប្បន្ន សមិទ្ធផលជាច្រើនក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ ត្រូវបានរាជរដ្ឋាភិបាលសម្រេចបាន ក្នុងនោះមាន៖ ផ្លូវជាតិ ផ្លូវខេត្ត ផ្លូវលំជនបទ ស្ពានឆ្លងកាត់ទន្លេ ស្ពានអាកាសក្នុងរាជធានីភ្នំពេញ។ល។ ជាក់ស្តែង ក្នុងឆ្នាំ២០១៨កន្លងទៅ រាជរដ្ឋាភិបាលបានដាក់ឲ្យដំណើរការផ្លូវជាតិលេខ៦ ដែលមានប្រវែង **២៤៨,៥៣គីឡូម៉ែត្រ** ចាប់ពីថ្នល់កែងខេត្តកំពង់ចាម ដល់អង្ក្រង ខេត្តសៀមរាប ផ្លូវជាតិលេខ៥៨ ដែលមានប្រវែង **១៧៤,១៦គីឡូម៉ែត្រ** ចាប់

ពីក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដល់ក្រុងសំរោង ខេត្តឧត្តរមានជ័យ ចំណតកំពង់ផែពហុបំណងនៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ស្ពានឆ្លងកាត់ព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ ពីភូមិស្ទឹងបត់ ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ទៅភូមិណងអៀន ស្រុកអារញ្ញប៉ាវ៉ែត ខេត្តស្រះកែវ ដែលមានប្រវែង **១៣០ម៉ែត្រ** ស្ពានមិត្តភាពកម្ពុជា ជប៉ុន(ស្ពានជ្រោយចង្វារទី១) ដែលមានប្រវែង **៩៧១ម៉ែត្រ** ថ្មីៗនេះ និងការបើកការដ្ឋានស្ថាបនាផ្លូវល្បឿនលឿនពីភ្នំពេញទៅក្រុងព្រះសីហនុ ដែលមានប្រវែង **១៩០គីឡូម៉ែត្រ** តភ្ជាប់ពីភូមិ១ សង្កាត់សំរោងក្រោម ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដល់ភូមិ១ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩ ហើយចំណាយថវិកាប្រមាណ **២៣ន់លានដុល្លារអាមេរិក** ក្រោមរូបភាពសាងសង់ ធ្វើអាជីវកម្ម និងផ្ទេរ(B.O.T.) ដែលនឹងគ្រោងបញ្ចប់រយៈពេល៤៨ខែ ជាដើម។

ចំពោះវិស័យថាមពលអគ្គិសនីវិញ នៅឆ្នាំ២០១៨កន្លងទៅ បរិមាណផ្គត់ផ្គង់ដោយវារីអគ្គិសនី និងរោងចក្រអគ្គិសនីដុតធ្យូងថ្ម ដែលជាប្រភពថាមពលផ្ទាល់របស់កម្ពុជា សម្រេចបានជាង **៩,៦ន់លាន** គីឡូវ៉ាត់ម៉ោង បានកើនឡើងប្រមាណ **២៤,៨៩%** បើប្រៀបធៀបនឹងឆ្នាំ២០១៧។ ការតភ្ជាប់ខ្សែបណ្តាញចរន្ត ឲ្យដល់ប្រជាពលរដ្ឋជាអ្នកប្រើប្រាស់ថាមពលអគ្គិសនីរហូតមកដល់ឆ្នាំ២០១៨នេះ ចំពោះគេហដ្ឋានប្រជាពលរដ្ឋសុទ្ធសាធ បានកើនដល់ប្រមាណ **២,៥៥លានខ្នងផ្ទះ** ត្រូវជាប្រមាណ **៧២,១៦%** នៃចំនួនផ្ទះសរុបប្រមាណ **៣,៣៨លានខ្នង** និងគ្របដណ្តប់ដល់ភូមិប្រមាណ **៨៧%** នៃចំនួនភូមិសរុប **១៤ ៣៨៣ភូមិ** នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ ជាក់ស្តែង ក្នុងឆ្នាំ២០១៨កន្លងទៅ រាជរដ្ឋាភិបាលបានដាក់ឲ្យដំណើរការវារីអគ្គិសនីសេសានក្រោម២ មានអានុភាព**៤០០មេហ្គាវ៉ាត់** នៅស្រុកសេសាន ខេត្តស្ទឹងត្រែង។

ក្នុងឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ កន្លងទៅនេះដែរ ដោយសារអាកាសធាតុមានលក្ខណៈអំណោយផលល្អសម្រាប់ការបង្កបង្កើនផលដំណាំស្រូវនៅទូទាំងព្រះរាជាណាចក្រកម្ពុជា បានធ្វើឲ្យបរិមាណផលិតផលស្រូវរដូវវស្សានិងស្រូវរដូវប្រាំង សម្រេចបានប្រមាណជាង**១០,៦លានតោន** កើនឡើងជាងផលិតផលស្រូវវស្សានិងស្រូវរដូវប្រាំងក្នុងឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ប្រមាណ **២,៦៣%** និងសល់ស្រូវជាង **៦,២លានតោន** គិតជាអង្ករប្រមាណជាង **៤លានតោន** សម្រាប់បម្រើឱ្យការនាំចេញ។ រីឯការនាំចេញអង្ករទៅទីផ្សារបរទេសបានជាង **៦២ម៉ឺនតោន**។

រហូតមកដល់បច្ចុប្បន្ន នៅព្រះរាជាណាចក្រកម្ពុជា វិស័យឧស្សាហកម្មនិងសិប្បកម្មបានរីកលូតលាស់ជាបន្តបន្ទាប់។ រោងចក្រសរុបមានចំនួនជាង **១ ៥០០រោងចក្រ** ដែលភាគច្រើនជារោងចក្រកាត់ដេរសម្លៀកបំពាក់ ស្បែកជើង និងមានឧស្សាហកម្មមធ្យម តូច និងសិប្បកម្មជាង **១៥៦ ៨៩០មូលដ្ឋាន** ហើយដែលបានស្រូបកម្លាំងពលករសរុបប្រមាណជាង **១លាននាក់**។ ស្របនឹងការរីកចម្រើនវិស័យឧស្សាហកម្ម និងសិប្បកម្ម រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់លើជីវភាពរស់នៅចំពោះកម្មករ និយោជិត ដោយបានដំឡើងប្រាក់ឈ្នួលអប្បបរមាជូនកម្មករ និយោជិត ផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងកើនឡើងដល់ **១៨២ដុល្លារអាមេរិក** ហើយបើក២ដងក្នុងមួយខែ នៅឆ្នាំ២០១៩ ដោយមិនទាន់គិតទៅដល់ការទទួលបាននូវអត្ថប្រយោជន៍បន្ថែមផ្សេងៗទៀត ពីការអនុវត្តគោលនយោបាយ គាំពារសង្គមរបស់រាជរដ្ឋាភិបាល។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលបានគិតគូរ និងដោះស្រាយជូនបងប្អូន និយោជិត កម្មករ កម្មការិនីនូវអត្ថប្រយោជន៍ ជាច្រើនទៀតដូចជាការពិនិត្យសុខភាព ការព្យាបាលជំងឺដោយមិនគិតថ្លៃនៅតាមមន្ទីរពេទ្យរបស់រដ្ឋ ការផ្តល់នូវរបបឧបត្ថម្ភមាតុភាពចំនួន**៤០ម៉ឺនរៀល** សម្រាប់ការសម្រាលបានកូនមួយ និងការធ្វើដំណើរតាមរថយន្តក្រុងសាធារណៈមិនគិតថ្លៃផងដែរ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលក៏បាន និងកំពុងជួយពលករកម្ពុជាដែលធ្វើការនៅបរទេសមានប្រមាណ**ជាង ១,២លាននាក់** មានជាអាទិ៍ ប្រទេសថៃ សាធារណរដ្ឋកូរ៉េ ប្រទេសម៉ាឡេស៊ី ជប៉ុន សិង្ហបុរី និងហុងកុង ក្នុងការធានានូវផលប្រយោជន៍ស្របច្បាប់ និងមុខជំនាញបច្ចេកទេស។

វិស័យសំណង់រីកលូតលាស់ ដោយមានអគារខ្ពស់ៗប្រមាណជាង **១០៨០អគារ** ចាប់ពី៥ជាន់ទៅ៤០ជាន់ឡើង ក្នុងរាជធានីភ្នំពេញ និងនៅតាមបណ្តាខេត្តមួយចំនួន។ ភ្ញៀវទេសចរអន្តរជាតិក៏បានចូលមកព្រះរាជាណាចក្រកម្ពុជា មានចំនួនប្រមាណ**ជាង ៦លាន២សែននាក់** កើនឡើង ប្រមាណ **១០,៧%**

បើធៀបនឹងឆ្នាំ២០១៧ បានបង្កើតការងារដោយផ្ទាល់ដល់ប្រជាពលរដ្ឋកម្ពុជា មានប្រមាណ **ជាង ៦២ម៉ឺននាក់** និងដោយប្រយោលប្រមាណ**ជាង ១លាននាក់**។ ចំណូលពីវិស័យទេសចរណ៍ បានប្រមាណ **៤ ៣៥៦លានដុល្លារអាមេរិក** មានការកើន **១៥,១៣%** ហើយចំណូលពីការលក់បណ្ណចូលទស្សនារមណីយដ្ឋានអង្គរទទួលបានប្រមាណ **១១៦លានដុល្លារអាមេរិក** ដែលមានភ្ញៀវទេសចរអន្តរជាតិចូលទស្សនាប្រមាណ **២,៦**លាននាក់ កើន **៥,៤៥%** បើធៀបនឹងឆ្នាំ២០១៧។ នេះសបញ្ជាក់ឲ្យឃើញពីការរក្សាបាននូវសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាព និងសន្តិភាពនៅទូទាំងប្រទេស ដោយអនុវត្តនូវវិធានការច្បាប់ដ៏ម៉ឺងម៉ាត់របស់រាជរដ្ឋាភិបាល។

ចំពោះការងារការបរទេសវិញ រាជរដ្ឋាភិបាលបានខិតខំបំពេញបេសកកម្មការទូតនៅលើឆាកអន្តរជាតិ និងកិច្ចសហប្រតិបត្តិការអន្តរជាតិលើគ្រប់វិស័យ ដោយទទួលបាននូវលទ្ធផលប្រកបដោយផ្លែផ្កា ជាអាទិ៍ កិច្ចប្រជុំទូទៅលើកទី៧៣នៃមហាសន្និបាតអង្គការសហប្រជាជាតិ កាលពីថ្ងៃទី២៧ ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៨ នៅទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក និងកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប (ASEM) លើកទី១២ កាលពីថ្ងៃទី១៨ ដល់ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៨ នៅទីក្រុងព្រុចសែល ប្រទេសបែលហ្ស៊ីក ហើយកិច្ចប្រជុំនេះក៏បានអនុម័តគាំទ្រឲ្យព្រះរាជាណាចក្រកម្ពុជា ធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប លើកទី១៣ ឆ្នាំ២០២០។ ទន្ទឹមនេះ រាជរដ្ឋាកិបាលកម្ពុជា ក៏បានចូលរួមចំណែកបញ្ជូនកងយោធពលខេមរភូមិន្ទជាបន្តបន្ទាប់ទៅចូលរួមបំពេញបេសកកម្មក្រោមឆ័ត្រអង្គការសហប្រជាជាតិ នៅសាធារណរដ្ឋលីបង់ សាធារណរដ្ឋស៊ូដង់ខាងត្បូង សាធារណរដ្ឋម៉ាលី និងសាធារណរដ្ឋអាហ្វ្រិកកណ្តាល ដែលមកដល់បច្ចុប្បន្នមានចំនួន ៨១៣នាក់ ក្នុងនោះស្រី ៦៦នាក់។

សម្តេចព្រះអគ្គមហាសង្ឆរាជាធិបតី សម្តេចព្រះសង្ឆរាជ សម្តេចព្រះរាជាគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីសក្តារៈ សម្តេច ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ជាទីមេត្រី បងប្អូនជនរួមជាតិទាំងអស់ជាទីស្នេហា

រាល់សមិទ្ធផលដែលរាជរដ្ឋាកិបាលសម្រេចបានកន្លងទៅនេះ គឺអាស្រ័យដោយមានការដឹកនាំខាងនយោបាយត្រឹមត្រូវ ប្រកបដោយធនធ:ម្ចោះមុត មានការចូលរួមគាំទ្រពីសមាជិក សមាជិកានៃស្ថាប័ននីតិប្បញ្ញត្តិ សមាជិក សមាជិការាជរដ្ឋាកិបាល មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ក្នុងការបំពេញការកិច្ចរបស់ខ្លួន និងការគាំទ្រយ៉ាងពេញទំហឹងពីប្រជាពលរដ្ឋទូទាំងប្រទេស ព្រមជាមួយនិងការជួយឧបត្ថម្ភគាំទ្រដោយចិត្តស្មោះសពីបណ្តាប្រទេសជាមិត្ត ដៃគូអភិវឌ្ឍន៍ និងសហគមន៍អន្តរជាតិផងដែរ។

ឆ្លៀតក្នុងឱកាសនេះដែរ ទូលបង្គំ ខ្ញុំព្រះករុណា ខ្ញុំ សូមអំពាវនាវដល់អង្គបោះឆ្នោតទាំងអស់ ដែលជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងមុខតំណែង សូមអញ្ជើញទៅចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៣ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃអាទិត្យ ទី២៦ ខែឧសភា ឆ្នាំ២០១៩ ខាងមុខឲ្យបានគ្រប់ៗគ្នាកុំបីខាន ដើម្បីអនុវត្តសិទ្ធិក្នុងឋានៈជាម្ចាស់ជោគវាសនានៃប្រទេសជាតិរបស់ខ្លួន។

សម្រាប់ឆ្នាំថ្មី ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ រាជរដ្ឋាកិបាលនៃព្រះរាជាណាចក្រកម្ពុជានឹងខិតខំពុះពារគ្រប់បែបយ៉ាងជាបន្តទៀត ដើម្បីបន្តថែរក្សាការពារសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ ឲ្យបានកាន់តែរឹងមាំ ការពាររដ្ឋធម្មនុញ្ញ ការពាររបបរាជានិយម ស្របតាមបាវចនា ជាតិ សាសនា ព្រះមហាក្សត្រ និងការពាររាល់សមិទ្ធផលដែលរាជរដ្ឋាកិបាល និងប្រជាពលរដ្ឋទាំងមូលសម្រេចបាននាពេលកន្លងទៅ។ ទន្ទឹមនេះ រាជរដ្ឋាកិបាលនឹងបន្តការធ្វើកំណែទម្រង់រដ្ឋដ៏ស៊ីជម្រៅតាមអភិក្រម "**ឆ្នុះកញ្ចក់ ងូតទឹក ជុះក្អែល ញ្យាបាល និងវះកាត់**" ក្នុងនោះមានការពង្រឹងអភិបាលកិច្ចល្អ តាមរយៈការពង្រឹងស្ថាប័នជាតិ និងថ្នាក់ក្រោមជាតិ ការធ្វើកំណែទម្រង់រ៉ែមជ្ឈការនិងវិសហមជ្ឈការ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ការអភិវឌ្ឍធនធានមនុស្ស ការកែលម្អប្រព័ន្ធអប់រំឲ្យកាន់តែមានគុណភាពខ្ពស់ ការលើកកម្ពស់ប្រព័ន្ធការពារសង្គម ការលើកកម្ពស់គុណភាពសេវាសុខាភិបាល និងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត សំណង់ ផ្លូវ ស្ពាន

និងធារាសាស្ត្រ បង្កើនប្រភពថាមពលអគ្គិសនី អភិវឌ្ឍវិស័យឧស្សាហកម្ម សិប្បកម្ម សេវាកម្មដឹកជញ្ជូន ពាណិជ្ជកម្ម ទេសចរណ៍ និងវិស័យកសិកម្ម ឲ្យកាន់តែរីកចម្រើនឥតឈប់ឈរថែមទៀត។

សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះសង្ឃរាជ សម្តេចព្រះរាជាគណៈ ព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គជាទីសក្ការៈ សម្តេច ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ជាទីមេត្រី បងប្អូនជនរួមជាតិទាំងអស់ជាទីស្នេហា

ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ នេះ ក្នុងនាមរាជរដ្ឋាភិបាល និងក្នុងនាមទូលបង្គំជាខ្ញុំ ព្រមទាំងមន្ត្រីរាជការ កងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ និងបងប្អូនជនរួមជាតិទាំងអស់ ទូលបង្គំជាខ្ញុំ សូមលំនិនកាយវាចាចិត្ត គោរពបួងសួងដល់គុណបុណ្យព្រះរតនត្រ័យកែវទាំងបីវត្ថុស័ក្តិសិទ្ធិក្នុងលោក ទេវតាឆ្នាំថ្មី ព្រះនាម **ទុច្ឆាទេវី** សូមប្រោះព្រំសព្វសាធុការពរ បវរមហាប្រសើរ ចំពោះព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត និងសម្តេចព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូ និងសុភមង្គល សូមព្រះអង្គមានព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ព្រះរាជសុខភាពបរិបូណ៌ ព្រះកាយពលមាំមួន ព្រះបញ្ញាញាណភ្លឺថ្លា ដើម្បីបានគង់ប្រថាប់នៅក្នុងព្រះបរមសិរីរាជសម្បត្តិ ជាម្លប់ដ៏ត្រជាក់នៃប្រជាពលរដ្ឋខ្មែរ ជាកូន ជាចៅ ចៅទួត ជានិច្ចនិរន្តរ៍តរៀងទៅ។

ក្នុងឱកាសដ៏មហានក្ខត្តឫក្សនេះដែរ ក្នុងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងក្នុងនាមទូលបង្គំ ខ្ញុំព្រះករុណា សូមប្រគេនព្រះពរចំពោះសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះសង្ឃរាជ សម្តេចព្រះរាជាគណៈ និងព្រះសង្ឆគ្រប់ព្រះអង្គ សូមមានព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា មានព្រះសុខភាពល្អបរិបូណ៌ ព្រះកាយពលមាំមួន ព្រះបញ្ញាញាណភ្លឺថ្លា ដើម្បីបានគង់ប្រថាប់ជាម្លប់របស់ពុទ្ធបរិស័ទក្នុងព្រះរាជាណាចក្រកម្ពុជាជានិច្ចនិរន្តរ៍តរៀងទៅ និងសូមជូនពរដល់ជនរួមជាតិខ្មែរគ្រប់រូបដែលកំពុងរស់នៅក្នុងនិងក្រៅប្រទេស មន្ត្រីរាជការ នាយទាហាន ពលទាហាននៃកងយោធពលខេមរភូមិន្ទ ដែលបាននិងកំពុងបំពេញការកិច្ចការពារអធិបតេយ្យ បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា និងកំពុងបំពេញបេសកកម្មរក្សាសន្តិភាព និងមនុស្សធម៌នៅក្រៅប្រទេស នាយនគរបាល ពលនគរបាលដែលបាន និងកំពុងរួមចំណែកការពារបូរណភាពទឹកដី និងថែរក្សាការពារសន្តិភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈនៃមាតុភូមិ ក្មួយៗសិស្សានុសិស្ស និស្សិត យុវជន យុវនារី កម្មករ និយោជិត ធុរជន និងវិនិយោគិនដែលកំពុងប្រកបធុរកិច្ចនៅលើទឹកដីកម្ពុជា សូមទទួលបាននូវភាពជោគជ័យ សិរីសួស្តី ជ័យមង្គល និងវិបុលសុខជាដរាបតរៀងទៅ។

សូមទេវតាឆ្នាំថ្មី ព្រះនាម **ទុច្ឆាទេវី** ជួយអភិបាលគ្រប់គ្រង ជួយបីបាច់ថែរក្សាគាំពារ និងប្រសិទ្ធពរជ័យដល់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ឲ្យមានសមានចិត្តជាកុសល យោគយល់គ្នា រួបរួមសាមគ្គីគ្នាជាមហាគ្រួសារខ្មែរតែមួយនៅលើទឹកដីមាតុភូមិអង្គរជាទីស្នេហា ដោយសេចក្តីសុខក្សេមក្សាន្ត និងប្រកបដោយកិត្តិយស សេចក្តីថ្លៃថ្នូ តរៀងទៅ។

សូមអរព្រះគុណនិងអរគុណ!

ថ្ងៃ ពុធ ១៤រោច ខែ ចិត្ត ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១ ខែ មេសា ឆ្នាំ២០១៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន